ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តក្រចេះ**
សំណុំរឿងរដ្ឋប្បវេណី
លេខ៨៧/ ០៦.៧.២០២០
សាលក្រមលេខ៩៧ (យ)
ចុះថ្ងៃទី២៣.៩.២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តក្រចេះ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ពីរពាន់ម្ភៃ វេលាម៉ោងដប់សាមសិបនាទីព្រឹក
និងប្រកាស់សាលក្រមនៅម៉ោងពីរសាមសិបនាទីរសៀល។

**ចៅក្រមជំនុំជម្រះ**
លោក [redacted] ចៅក្រមសាលាដំបូងខេត្តក្រចេះ

**ក្រឡាបញ្ជីសវនាការ**
លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ

ដើមចោទឈ្មោះ [redacted] **ចិន្តា** ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ [redacted]

មេធាវីតំណាងដោយអាណត្តិដើមចោទ : លោកមេធាវី [redacted] (អត្តលេខ [redacted] ជាគ្រូកម្មសិក្សា) និង លោកមេធាវី [redacted] (អត្តលេខ [redacted] ជាសិស្សកម្មសិក្សា ) ការិយាល័យមេធាវី [redacted] អាស័យដ្ឋាន [redacted] ។

ចុងចម្លើយឈ្មោះ [redacted] **សូនី** ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ ទីលំនៅ [redacted] ។

**អង្គហេតុ និង ចំណុចវិវាទ**

**១-ការទាមទាររបស់ដើមបណ្តឹង :**

-សុំផ្តាច់សមគ្គសង្វាសពីប្តី

-សុំគ្រប់គ្រងកូនប្រុសម្នាក់ឈ្មោះ ហម សុវណ្ណារិទ្ធ កើតថ្ងៃទី១១.១២.២០១៣

-សុំប្រគល់រថយន្តកែឆ្នៃចំនួន១គ្រឿងអោយទៅឈ្មោះ ហម សូនី ជាប្តីគ្រប់គ្រង

-សុំអោយចុងចម្លើយផ្តល់អាហារកិច្ចចិញ្ចឹមកូនក្នុង១ខែចំនួន៣០០$(បីរយដុល្លារ)

**២-ការអះអាងរបស់ភាគី :**

-ដើមចោទឈ្មោះ [redacted] **ចិន្តា** បានអះអាងថា : ខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] សូនី នៅឆ្នាំ១៩៩២ បានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ តាមសំបុត្រអាពាហ៍ពិពាហ៍លេខ៤៤ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ រួមរស់នៅជាមួយគ្នាមានកូន៣នាក់ ១.ឈ្មោះ ហម វលក្ខ័ ភេទស្រី កើតថ្ងៃទី០៥.០២.១៩៩២,

Scanned with CamScanner

២.ឈ្មោះ[redacted]រដ្ឋវណ្ណ ភេទស្រី កើតថ្ងៃទី ២៥.១១.១៩៩៤ ,៣.ឈ្មោះ[redacted]សុវណ្ណារិទ្ធ ភេទប្រុស កើតថ្ងៃទី ១១.១២.២០០៣ តែការរួមរស់មិនចុះសំរុងនឹងគ្នាដោយសារប្តីបានចុះចោលរយៈ៧ខែនិងមានស្រីផ្សេង ។ សំណូមពរសុំអោយតុលាការកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍ចាប់ពីពេលនេះតទៅ,សុំគ្រប់គ្រងកូនឈ្មោះ[redacted] សុវណ្ណារិទ្ធ ,សុំអោយចុងចម្លើយជួយផ្តល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព , ទ្រពសម្បត្តិរួមមានម៉ូតូឌ្រីម០១៧ ចំនួន១គ្រឿងសុំទុកអោយកូន,គ្រែចំនួន២, ហង្សតេចំនួន១, តាកាប៉ោងចំនួន២, ក្តារង្ងៀ៤សន្លឹក, ក្តារខ្នាវ៤០ សន្លឹក ឯកភាពចែកពាក់កណ្តាលម្នាក់ ,ឡានកែឆ្នៃចំនួន១គ្រឿងសុំប្រគល់អោយប្តី, ចំពោះការទាមទារចែកដី.ផ្ទះដែលខ្លួនកំពុងរស់នៅ ខ្លួនមិនឯកភាពទេព្រោះជាកេរឪពុកម្តាយខ្លួន , លុយជួសជុលធ្វើជណ្តើរផ្ទះ ធ្វើយ៉ាបផ្ទះ ប្រហែលជាងមួយពាន់ដុល្លារ ដើមចោទទាមទារចែកខ្លួនមិនឯកភាពទេ ព្រោះដី.ផ្ទះជាកេរឪពុកម្តាយខ្លួន ហើយចុងចម្លើយក៏បានខ្ចីលុយឪពុកខ្លួនចំនួន១៨០០ដុល្លារ(មួយពាន់ប្រាំបីរយ)ដែរ។

-ចុងចម្លើយឈ្មោះ[redacted] **សុទ្ធី** បានអះអាងថា : ខ្លួនយល់ព្រមលែងលះពីដើមចោទ ខ្លួនមានស្រីថ្មីមែន ឯកភាពប្រគល់សិទ្ធអោយដើមចោទគ្រប់គ្រងកូនឈ្មោះ[redacted]សុវណ្ណារិទ្ធ និងជួយផ្តល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព, ទ្រព្យសម្បត្តិរួមមាន ម៉ូតូ០១៧ចំនួន១គ្រឿងឯកភាពទុកអោយកូន , គ្រែ២សុំយកគ្រែប្រអប់១,តាកាប៉ោង២ចែក១ម្នាក់, ក្តារគគីចំនួន៤សន្លឹក ចែក២សន្លឹកម្នាក់,ក្តារខ្នាវ៤០សន្លឹកចែក២០សន្លឹកម្នាក់ ឯឡានកែឆ្នៃចំនួន១គ្រឿងនៅខ្លួនកំពុងគ្រប់គ្រង។ ចំពោះផ្ទះ.ដីខ្លួនទទួលស្គាល់កេរខាងប្រពន្ធ តែប្តូរឈ្មោះពីរនាក់ប្តីប្រពន្ធ និង លុយជួសជុលធ្វើផ្ទះអស់ប្រាក់ច្រើន សុំទាមទារបែងចែកតាមច្បាប់ ,លុយខ្ចីឪពុកក្មេកតែ ៨០០ដុល្លារ ។

**៣-ចំណុចវិវាទ :**

-ផ្ទះ និង ដីភូមិស្ថិតនៅភូមិរកាកណ្តាល១ សង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ តើជាទ្រព្យរួមប្តីប្រពន្ធ ឬ ជាទ្រព្យមរតករបស់ដើមចោទ ?

-ចុងចម្លើយទាមទារចែកផ្ទះ.ដី,លុយជួសជុលធ្វើផ្ទះ ដើមចោទមិនឯកភាព។

**៤-ចំណុចគ្មានវិវាទ :**

ដើមចោទ និង ចុងចម្លើយឯកភាពគ្នាលែងលះគ្នាដោយស្មគ្រ័ចិត្ត, ឯកភាពប្រគល់សិទ្ធគ្រងកូនម្នាក់អោយដើមចោទគ្រប់គ្រង ចុងចម្លើយជួយផ្តល់អាហារកិច្ចតាមលទ្ធភាព និង ឯកភាពចែកទ្រព្យសម្បត្តិរួមស្មើគ្នា។

## សំអាងហេតុ

ផ្អែកតាមសេចក្តីថ្លែងការណ៍របស់គូភាគីនៅក្នុងនីតិវិធីត្រៀម និង នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការយល់ឃើញថា :

-ដើមចោទឈ្មោះ[redacted]ចិន្តា និង ចុងចម្លើយឈ្មោះ[redacted]សុទ្ធី បានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ១៩៩២ ចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់តាមសំបុត្រអាពាហ៍ពិពាហ៍លេខ៤៤ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ ២០១២ ស្របតាមបទបញ្ញត្តិមាត្រា៩៥៥នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាលេខនស/រកម/១២០៧/០៣០ចុះថ្ងៃទី២៩ខែធ្នូឆ្នាំ២០០៧ និង មាត្រា២៨,៣០,៤៥នៃអនុក្រិត្យស្តីពីអត្រានុកូលដ្ឋានលេខ១០៣ អនក្រ.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០។

Scanned with CamScanner

-ដើមចោទប្តឹងសុំផ្តាច់សមគ្គសង្វាសពីចុងចម្លើយជាប្តី ដោយសារប្តីមានស្រីផ្សេងរួមរស់នៅពុំចុះសំរុងនឹងគ្នា , ចុងចម្លើយយល់ព្រមលែងលះពីដើមចោទជាប្រពន្ធ ឃើញថាគូភាគីអស់មនោសញ្ចេតនារវាងគ្នាហើយ ដូច្នេះតុលាការសំរេចអោយលែងលះគ្នាតាមឆន្ទះរបស់គូភាគី ។

-តាមបញ្ញត្តិមាត្រា៩៥០ ចំណុច១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ភាគីស្ត្រីដែលត្រូវបានលែងលះពីប្តីត្រូវស្ថិតនៅក្នុងភាពម៉េម៉ាយចំនួន១២០ថ្ងៃ ប៉ុន្តែអង្គហេតុនេះដើមចោទនិងចុងចម្លើយបានរស់នៅបែកលំនៅសង្វាសរវាងគ្នាប្រមាណ៧ខែមកហើយ ដូច្នេះតុលាកាពុំសំរេចគ្រង់ចំណុចនេះឡើយ។

-ក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាដើមចោទ និង ចុងចម្លើយមានកូនចំនួន៣នាក់ ១.ឈ្មោះ [redacted] វលក្ខ័ ភេទស្រី កើតថ្ងៃទី ០៥.០២.១៩៩២, ២.ឈ្មោះ [redacted] រដ្ឋវណ្ណ ភេទស្រី កើតថ្ងៃទី ២៥.១១.១៩៩៤ និង ៣.ឈ្មោះ [redacted] សុវណ្ណារិទ្ធ ភេទប្រុស កើតថ្ងៃទី១១.១២.២០០៣, កូនឈ្មោះ [redacted] វលក្ខ័ និង ឈ្មោះ [redacted] រដ្ឋវណ្ណ មាននីតិភាព , ដើមចោទសុំសិទ្ធគ្រប់គ្រងកូនឈ្មោះ [redacted] សុវណ្ណារិទ្ធ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ១១.១២.២០០៣ (អនីតិភាព) និង សុំអោយចុងចម្លើយជួយផ្តល់អាហារកិច្ចតាមលទ្ធភាព ,ចុងចម្លើយឯកភាព ដូច្នេះគប្បីតុលាការពិចារណាសំរេចផ្តល់អំណាចមេបាក្នុងការគ្រប់គ្រងកូនអោយទៅដើមចោទតាមឆន្ទះរបស់គូភាគី និង បង្គាប់អោយចុងចម្លើយជួយផ្តល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាពរបស់ខ្លួន។

-ឪពុកម្តាយដែលលែងលះគ្នាមានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន និង ការបង់អាហារកាតព្វកិច្ចកូន ហើយដើមចោទដែលជាអ្នកមានអំណាចមេបាលើកូនត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ចុងចម្លើយក្នុងការទំនាក់ទំនងនិងសួរសុខទុកកូន ស្របតាមបញ្ញត្តិមាត្រា១០៣៧,១០៤០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា២២នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

-ទ្រព្យសម្បត្តិរួមមាន : ម៉ូតូឌ្រីម០១៧ចំនួន១គ្រឿងដើមចោទនិងចុងចម្លើយឯកភាពទុកអោយកូន ហើយដើមចោទ និង ចុងចម្លើយបានព្រមព្រៀងគ្នាបែងចែក គឺដើមចោទព្រមទទួលយកគ្រែចំនួន១, ហង្សតេចំនួន១, តាកាប៉ោងចំនួន១, ក្តារវៀចំនួន២សន្លឹក និង ក្តារខ្វាវចំនួន២០សន្លឹក , ឯចុងចម្លើយព្រមទទួលយកគ្រែប្រអប់ចំនួន១, តាកាប៉ោងចំនួន១, ក្តារវៀចំនួន២សន្លឹក ក្តារខ្វាវចំនួន២០សន្លឹក និង រថយន្តកែច្នៃចំនួន១គ្រឿង ដូច្នេះតុលាការនឹងធ្វើការបែងចែកទ្រព្យសម្បត្តិរួមតាមការព្រមព្រៀង , ដោយឡែកផ្ទះ:ដីភូមិស្ថិតនៅភូមិរកាកណ្តាល១ សង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ ដែលដើមចោទកំពុងរស់នៅ ដើមចោទបានអះអាងថាជាកេរមរតកឪពុកម្តាយខ្លួន ,ចុងចម្លើយទទួលស្គាល់ថាជាកេររបស់ដើមចោទតែទាមទារអោយបែងចែកដោយសារប្តូរចុះឈ្មោះប្តីប្រពន្ធនិងទាមទារចែកលុយជួសជុលធ្វើផ្ទះ ប៉ុន្តែដើមចោទមិនឯកភាពដោយបានអះអាងថា លុយធ្វើផ្ទះអស់តែ១៣០០ដុល្លារ ឯចុងចម្លើយខ្ចីលុយឪពុកខ្លួន១៨០០ដុល្លារ ចុងចម្លើយទទួលស្គាល់បានខ្ចីលុយឪពុកក្មេកតែចំនួន៨០០ដុល្លារ , ចំណុចនេះតុលាការមិនលើកមកពិចារណាឡើយ ពីព្រោះដើមចោទបានអះអាងសមហេតុផល ហើយចុងចម្លើយក៏មិនមានភស្តុតាងឯកសារបញ្ជាក់ដែលគប្បីអោយតុលាការលើកមកពិចារណាឡើយ ។

-បន្ទុកលើប្រាក់ប្រដាប់ក្តីគប្បីអនុវត្តតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី។

Scanned with CamScanner

**សេចក្តីសម្រេចបញ្ចប់ :**

១-អោយដើមចោទឈ្មោះ [redacted] **ចិន្តា** ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ ដាច់សមគ្គសង្វាសពីចុងចម្លើយឈ្មោះ [redacted] **សូនី** ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ ចាប់ពីសាលក្រមនេះចូលជាស្ថាពរ។

២-រំលាយចោលសំបុត្រអាពាហ៍ពិពាហ៍លេខ ៤៤ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ របស់មន្រ្តីអត្រានុកូលដ្ឋាន សង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ ចាប់ពីសាលក្រមនេះចូលជាស្ថាពរ។

៣-ប្រគល់សិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] **សុវណ្ណារិទ្ធ** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត១១.១២.២០០៣ អោយដើមចោទឈ្មោះ [redacted] ចិន្តា ជាម្តាយគ្រប់គ្រងបីបាច់ថែរក្សារហូតដល់កូនមាននីតិភាព និងបង្គាប់អោយចុងចម្លើយឈ្មោះ [redacted] សូនី ជាឪពុកជួយផ្តល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព។

-ទុកសិទ្ធិអោយចុងចម្លើយឈ្មោះ [redacted] **សូនី** ជាឪពុក មានសិទ្ធិចូលជួបប្រាស្រ័យសួរសុខទុក្ខទាក់ទងកូនបាន ,ចុងចម្លើយឈ្មោះ [redacted] **ចិន្តា** ត្រូវបង្កលក្ខណៈងាយស្រួលរវាងគ្នានៅពេលសួរសុខទុក្ខកូនស្របតាមបញ្ញត្តិមាត្រា១០៣៧,១០៤០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា២២នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

៤-ទ្រព្យសម្បត្តិរួមត្រូវបែងចែក :

ក.ប្រគល់អោយដើមចោទ : ម៉ូតូសង់០១៧ចំនួន១គ្រឿង, គ្រែចំនួន១, ហង្សគេចំនួន១, តាកាប៉ោងចំនួន១, ក្តារវៀចំនួន២សន្លឹក(គគី) និង ក្តារខ្វាវចំនួន២០សន្លឹក គ្រប់គ្រងចាប់ពីសាលក្រមនេះចូលជាស្ថាពរ។

ខ.ប្រគល់អោយចុងចម្លើយ : រថយន្តកែឆ្នៃចំនួន១គ្រឿង, គ្រែប្រអប់ចំនួន១, តាកាប៉ោងចំនួន១, ក្តារវៀចំនួន២សន្លឹក(គគី) និង ក្តារខ្វាវចំនួន២០សន្លឹក គ្រប់គ្រងចាប់ពីសាលក្រមនេះចូលជាស្ថាពរ។

៥-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៣ខែកញ្ញា ឆ្នាំ២០២០វេលាម៉ោងដប់សាមសិបនាទីព្រឹក និង ប្រកាសជាសាធារណៈនៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០២០ វេលាម៉ោងពីរសាមសិបនាទីរសៀល ។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគី។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ៦កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅក្រចេះ,ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខានិងត្រា: [redacted]

---

**បានឃើញ**

ថ្ងៃពុធ ៦កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ក្រចេះ,ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០២០

**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៦កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ក្រចេះ,ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner